# អារាធនាសីល ៥

មយំ ភន្តេ, វិសុំ វិសុំ រក្ខនត្ថាយ, តិសរណេន សហ, បញ្ច សីលានិ យាចាម ។ ទុតិយម្បិ មយំ ភន្តេ, វិសុំ វិសុំ រក្ខនត្ថាយ, តិសរណេន សហ, បញ្ច សីលានិ យាចាម ។ តតិយម្បិ មយំ ភន្តេ, វិសុំ វិសុំ រក្ខនត្ថាយ, តិសរណេន សហ, បញ្ច សីលានិ យាចាម ។

## បាលីបូជាចង្ហាន់ព្រះ

ឥមំ, សូប ព្យញ្ជនសម្បន្នំ, សាលីនំ, ឱទនំ, ឧទកំ វរំ, ពុទ្ធស្ស, បូជេមិ ។

## បាលីសុំចង្ហាន់ព្រះ

សេសំ មង្គលំ យាចាមិ ។

## បាលីថ្វាយសង្ឃទានធម្មតា

ឥមានិ មយំ ភន្តេ, ភត្តានិ, សបរិវារានិ, ភិក្ខុសង្ឃស្ស, ឱណោជយាម, សាធុ នោ ភន្តេ, ភិក្ខុសង្ឃោ, ឥមានិ, ភត្តានិ, សបរិវារានិ, បដិគ្គណ្ហាតុ, អម្ហាកំ, ទីឃរត្តំ, ហិតាយ, សុខាយ ។

## បាលីថ្វាយសង្ឃទានឧទ្ទិសជូនញាតិកាដែលចែកឋាន

ឥមានិ មយំ ភន្តេ, មតកភត្តានិ, សបរិវារានិ, ភិក្ខុសង្ឃស្ស, ឱណោជយាម, សាធុ នោ ភន្តេ, ភិក្ខុសង្ឃោ, ឥមានិ, មតកភត្តានិ, សបរិវារានិ, បដិគ្គណ្ហាតុ, អម្ហាកញ្ចេវ, មាតាបិតុអាទីនញ្ច, ទីឃរត្តំ, ហិតាយ, សុខាយ ។

# ពរប្រាំប្រការ

*អវសានេ ខ្ញុំអ្នកសរសេរ សូមជូនពុទ្ធពរ*
*ដល់លោកអ្នកអាន បានសម្បត្តិល្អ នោះគឺជាធម៌*
*ពរប្រាំប្រការ ។*
*ទីមួយ ជន្មា លោកអ្នករាល់គ្នា ជាងរយវស្សា*
*ដោយអំណាចបុណ្យ គុណត្រៃរតនា តាមជួយរក្សា*
*ថែទាំរាល់ថ្ងៃ ។*
*ទីពីរ វណ្ណៈ សម្បុរលោកអ្នក ចែងចាំងរស្មី*
*ភ្លឺថ្លាត្រចះ មើលគ្មានទាស់អ្វី នៅក្នុងលោកិយ៍*
*ល្បាញល្បីកេរ្តិ៍ឈ្មោះ ។*
*សក់ខ្មៅរលោង ស្បែកស្ដើងរលីង រលើបគ្មានទាស់*
*ត្រចៀកមិនថ្លង់ ភ្នែកក៏ភ្លឺច្បាស់ អាយុក្រែលក្រាស់*
*តែធ្មេញរឹងមាំ ។*
*ទីបី សុខៈ ចម្រើនតាមថ្នាក់ ពីតូចដល់ធំ*
*រោគាកុំបី ឆ្លៀតចូលសម្ងំ រុករានបង្ខំ*
*ទ្រុឌទ្រោមកាយា ។*
*ចំណែកខាងចិត្ត សូមបានល្អពិត កុំមានទោសា*
*គំនុំគុំកួន ពួនក្នុងអាត្មា នាំអាពាធា*
*ព្យាធិញ្ញឹកញ្ញាប់*

*លោភៈផ្លូវចិត្ត　　កុំបីមកបៀត　　ឆ្វៀតមកបង្អាប់*
*វាចាពោលទៅ　　នូវអ្វីពុំស្រប　　នាំតែគេស្អប់*
*គេធុញគេទ្រាន់ ។*
*មោហៈផងដែរ　　ចូរកុំជ្រៀតជ្រែ　　ជ្រៅក្នុងសន្តាន*
*ទោះបីមានមក　　ពីមុនប៉ុន្មាន　　គួរតែរុញច្រាន*
*ទើបបានសុខា ។*
*ទីបួន ពលៈ　　កម្លាំងលោកអ្នក　　មាំមួនខ្លាំងក្លា*
*ប្រៀបដូចកុលស្ត្រី　　យាយវិសាខា　　ចាប់ដរីសា*
*បោកដួលយ៉ាងងាយ ។*
*បដិភាណៈ　　ទីប្រាំចប់ដាក់　　សូមជូនមិនស្ពាយ*
*ជូនលោកអ្នកអាន　　ក្មេងចាស់ប្រុសស្រី　　ប្រាជ្ញាវាងវៃ*
*ថ្កើដជីវិតហោង ៕*

**វត្តចន្ទស៊ីសុធាវាស** 2312 E Spaulding St. LB., CA 90804
*ថ្ងៃទី ១០ ខែតុលា ព.ស. ២៥៥១ គ.ស. ២០០៧*

**ព្រះមហា ម៉ាសារិន វិសុទ្ធោ បរិញ្ញាបត្រជាន់ខ្ពស់ (M.A)**
**អតីតសាស្ត្រាចារ្យប្រវត្តិវិទ្យា នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត**
**ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**